**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ កពជ**
លេខ: ០៧៧០/ស.ជ.ក/២០២១

ថ្ងៃអង្គារ ៩កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០២១

**សូមជម្រាបមក**

**ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គមេបញ្ជាការរង មេបញ្ជាការកងទ័ពជើងគោក**
**ឯកឧត្តម នាយឧត្តមនាវី អគ្គមេបញ្ជាការរង មេបញ្ជាការកងទ័ពជើងទឹក**
**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការរង មេបញ្ជាការកងទ័ពជើងអាកាស**
**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការរង មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស**
**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការរង មេបញ្ជាការបញ្ជាការដ្ឋានអង្គរក្ស**
**ឯកឧត្តម នាយក ស្ថាប័ន និងកងឯកភាពចំណុះ ក្រសួងការពារជាតិ**
**ឯកឧត្តម នាយក ស្ថាប័ន និងកងឯកភាពចំណុះ អគ្គបញ្ជាការដ្ឋាន**

**កម្មវត្ថុ** ស្តីពីការចាក់វ៉ាក់សាំងលើកទី២ (វ៉ាក់សាំង SINOPHARM) ជូនយោធិន និងគ្រួសារ នៅតាមកងឯកភាពជុំវិញរាជធានីភ្នំពេញក្នុងដំណាក់កាលអនុវត្តវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ តាមគោលការណ៍របស់រាជរដ្ឋាភិបាល ។

**យោង** -សេចក្តីសម្រេចលេខ ៤៩សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

-សេចក្តីសម្រេចលេខ ៥០សសរ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកែសម្រួលវិធានការដែលត្រូវអនុវត្តក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

-សេចក្តីណែនាំលេខ ០១សណន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការលម្អិតដើម្បីរឹតបន្តឹងការអនុវត្តសេចក្តីសម្រេច ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

-លិខិតលេខ ០៩៥/២១ គ.ជ.ក១៩ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ បានប្រជុំពិភាក្សាការងារ នារសៀលថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ក្នុងនោះពិនិត្យឃើញថាពេលវេលាដែលត្រូវចាក់វ៉ាក់សាំងលើកទី២ ជូនកងទ័ព និងគ្រួសារ ដែលបានចាក់

លើកទី១ នៅតាមបណ្តាគោលដៅក្នុងនិងជុំវិញរាជធានីភ្នំពេញបានចូលមកដល់។ ស្ថិតក្នុងសភាពការណ៍ចាំបាច់ក្នុងការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមិនអនុញ្ញាតឲ្យធ្វើដំណើរឆ្លងពីខណ្ឌមួយទៅខណ្ឌមួយក្នុងរាជធានីភ្នំពេញ។ ហេតុនេះ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ សូមណែនាំដល់គ្រប់ប្រភេទទ័ព ទ័ពជំនាញ បណ្តាស្ថាប័ន កងឯកភាពចំណុះក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន ដូចខាងក្រោម៖

**១**.ចាត់ចែងធ្វើការផ្សព្វផ្សាយជាការប្រញាប់ដល់ស្ថាប័ន និងកងឯកភាពចំណុះ ដើម្បីជូនដំណឹងដល់យោធិននិងគ្រួសារ ដែលបានចាក់វ៉ាក់សាំងលើកទី១ នៅតាមទីតាំងនៅក្នុងនិងជុំវិញរាជធានីភ្នំពេញ ដើម្បីក្តាប់បានអំពីព័ត៌មាននៃកាលបរិច្ឆេទនិងទីតាំងចាក់វ៉ាក់សាំងលើកទី២ ព្រមទាំងឲ្យយោធិននិងគ្រួសារទាំងអស់ត្រូវរក្សាការទំនាក់ទំនងជាមួយសាមីអង្គភាព ដើម្បីសាកសួរនិងទទួលព័ត៌មានពាក់ព័ន្ធនេះ។ ទន្ទឹមនោះបន្តផ្សព្វផ្សាយឲ្យបងប្អូនប្រកាន់ខ្ជាប់ខ្លួនក្នុងការអនុវត្តវិធានសុខាភិបាល "**៣ការពារ ៣កុំ**" និងរក្សាសណ្តាប់ធ្នាប់សាធារណៈនៅតាមទីកន្លែងចាក់វ៉ាក់សាំងលើកទី២ ជំហានទី២ នៅគ្រប់ទីតាំងចាក់វ៉ាក់សាំងទាំងអស់។

មេបញ្ជាការកងឯកភាព ត្រូវក្តាប់ឲ្យបានចំនួនគ្រួសារយោធិន នៅតាមខណ្ឌនីមួយៗ និងត្រូវរាយការណ៍ជូននាយកដ្ឋានបុគ្គលិក(ស្ថាប័នចំណុះក្រសួងការពារជាតិ) ទីចាត់ការបុគ្គលិក(ស្ថាប័នកងឯកភាពចំណុះអគ្គបញ្ជាការដ្ឋាន) មុនថ្ងៃទី............ខែមេសា ឆ្នាំ២០២១។

ចាប់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ មានគោលដៅចាក់វ៉ាក់សាំងនឹងត្រូវចាប់ផ្តើមដំណើរការចាក់វ៉ាក់សាំងលើកទី២ ជូនកងទ័ព និងគ្រួសារ ដែលតម្រូវឱ្យបងប្អូនបង្ហាញប័ណ្ណចាក់វ៉ាក់សាំងលើកទី១ ទោះបីបងប្អូនចាក់នៅទីតាំងអង្គភាពណាក្តី ក្រុមការងារនឹងចាក់ជូនទាំងអស់ ក្នុងនោះមាន៖

**ក**.ក្រសួងការពារជាតិ៖ នៅមន្ទីរពេទ្យព្រះកេតុមាលា(វត្តភ្នំ)

**ខ**.កងឯកភាពចំណុះអគ្គបញ្ជាការដ្ឋាន៖ បញ្ជាការដ្ឋានកាំភ្លើងធំ(ព្រៃផ្តៅ) បញ្ជាការដ្ឋានបញ្ជូនសារ (កន្ទោក) បញ្ជាការដ្ឋានការពារអាកាស(ត្នាតពង) វិទ្យាស្ថានទ័ពជើងគោក(ថ្លុកតាសេក) បញ្ជាការដ្ឋានវិស្វកម្ម(ចោមចៅ និងផ្សារ) សាលានាយទាហានសកម្ម(ត្នាតពង) បញ្ជាការដ្ឋានរថក្រោះ(ស្រុកភ្នំស្រួច)

**គ**.កងទ័ពជើងគោក៖ បញ្ជាការដ្ឋានទ័ពពិសេស(កំបូល) កងពលតូចលេខ៧០(ចោមចៅ) កងពលតូចអន្តរាគមន៍លេខ១(លង្វែក) បញ្ជាការដ្ឋានការពារអាកាស(ភូមិព្រៃទា ចោមចៅ)

**ឃ**.កងទ័ពជើងទឹក៖ បញ្ជាការដ្ឋានកងទ័ពជើងទឹក(សាលាបឋមសិក្សាគៀនឃ្លាំង)

**ង**.កងទ័ពជើងអាកាស៖ បញ្ជាការដ្ឋានកងទ័ពជើងអាកាស( ពោធិចិនតុង )

**ច**.អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ បានរៀបចំទីតាំងចាក់វ៉ាក់សាំងចំនួន៣ សម្រាប់ចាក់វ៉ាក់សាំងជូនយោធិន និងគ្រួសារ ដែលរស់នៅក្នុងខណ្ឌចំនួន៣ ដូចខាងក្រោម៖

-នៅមន្ទីរពេទ្យជោរី (ជាប់បុរីប៉េងហួត បឹងស្នោរ) សម្រាប់ចាក់ជូនយោធិន និងគ្រួសារ ដែលរស់នៅក្នុងខ័ណ្ឌច្បារអំពៅ ដែលនឹងដំណើរការរយៈពេល៧ថ្ងៃ ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៨ ខែមេសាឆ្នាំ២០២១

-នៅក្នុងបុរីប្រេក្តានភ្នំពេញ (ជាប់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) សម្រាប់ចាក់ជូនយោធិន និងគ្រួសារ ដែលរស់នៅក្នុងខណ្ឌសែនសុខ ដែលនឹងដំណើរការរយៈពេលចាប់ពីថ្ងៃទី២១ ដល់២៥ ខែមេសា ឆ្នាំ២០២១

-នៅមុខឃ្លាំងប្រេងស្វាតីមិច (ព្រែកព្នៅ) សម្រាប់ចាក់ជូនយោធិន និងគ្រួសារ ដែលរស់នៅក្នុងខណ្ឌព្រែកព្នៅ ដែលនឹងដំណើរការរយៈពេល៧ថ្ងៃ ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែមេសាឆ្នាំ២០២១

**ឆ**.ចំពោះខណ្ឌទាំង១១ ផ្សេងទៀត អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នឹងបញ្ជូនក្រុមពេទ្យចល័ត ចុះចាក់វ៉ាក់សាំងលើកទី២ ជូនយោធិន និងគ្រួសារនៅតាមខណ្ឌនីមួយៗ នឹងជូនដំណឹងពេលវេលាជាក់ស្តែងតាមក្រោយ

**២**.ចំពោះបញ្ជាការដ្ឋានអង្គរក្ស ដែលបានរៀបចំទីកន្លែងចាក់វ៉ាក់សាំងលើកទី២ នៅស្នាក់ការ ភាគកបាទក្រហមកម្ពុជា សាខាខេត្តកណ្តាល (ក្រុងតាខ្មៅ) ដើម្បីចាក់ជូនយោធិន និងគ្រួសារ នៃអង្គភាពបញ្ជាការដ្ឋានអង្គរក្ស និងទទួលចាក់ជូនយោធិន និងគ្រួសារនៃអង្គភាពផ្សេងៗ ដែលមានទីស្នាក់អាស្រ័យនៅក្នុងក្រុងតាខ្មៅដោយផ្អែកតាមប័ណ្ណចាក់វ៉ាក់សាំងលើកទី១។ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នឹងបញ្ជូនក្រុមពេទ្យ និងផ្តល់វ៉ាក់សាំងជូនចាប់ពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១នេះ។

សូមគ្រប់កងឯកភាពដែលមានការពាក់ព័ន្ធដូចបានរៀបរាប់ខាងលើ ជូនដំណឹងយោធិននិងគ្រួសាររស់នៅក្នុងក្រុងតាខ្មៅធ្វើការទំនាក់ទំនងជាមួយក្រុមការងាររបស់បញ្ជាការដ្ឋានអង្គរក្សដើម្បីទទួលវ៉ាក់សាំងលើកទី២ តាមស្មារតីការជូនដំណឹងនេះ។

**៣**.ជាមួយគ្នានេះចាប់ពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ បញ្ជូនក្រុមការងារ(មានសមាសភាព នាយកដ្ឋានបុគ្គលិក និងទីចាត់ការបុគ្គលិក ដូចមានបញ្ជីឈ្មោះភ្ជាប់ជាមួយ) ចុះទៅសាលាខ័ណ្ឌទាំង១៤ក្នុងរាជធានីភ្នំពេញ ដើម្បីទទួលចុះឈ្មោះយោធិន និងគ្រួសារ (ដោយផ្អែកលើប័ណ្ណចាក់វ៉ាក់សាំងលើកទី១) ដែលត្រូវចាក់វ៉ាក់សាំងលើកទី២ ទោះបីចាក់លើកទី១នៅកងឯកភាពណាក៏ដោយ ព្រមទាំងជួយសម្របសម្រួលការងារពាក់ព័ន្ធ។ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ នឹងរៀបចំក្រុមពេទ្យចល័តចុះចាក់នៅតាមខណ្ឌតាមចំនួនជាក់ស្តែងដើម្បីរក្សានូវលក្ខខណ្ឌបច្ចេកទេសរបស់វ៉ាក់សាំងដែលតម្រូវមិនឱ្យលើស២៨ថ្ងៃ គិតចាប់ពីថ្ងៃចាក់លើកទី១ ។

**៤**.ចំពោះបណ្តាយោធភូមិភាគ បណ្តាកងពលធំ កងពលតូច បណ្តាតំបន់ប្រតិបត្តិការសឹករងខេត្ត បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ នឹងបន្តបញ្ជូនវ៉ាក់សាំងជូនសម្រាប់ដំណើរការចាក់ជូនយោធិន និងគ្រួសារតាមផែនការ និងសម្រាប់ចាក់ជូនយោធិននិងគ្រួសារដែលបានចាក់លើកទី១ នៅរាជធានីភ្នំពេញ ដែលមិនអាចវិលត្រឡប់មកចាក់នៅកន្លែងដើមបានវិញនោះ ។

**៥**.បណ្តាប្រភេទទ័ព ទ័ពជំនាញ បណ្តាស្ថាប័ន កងឯកភាពចំណុះក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋានត្រូវធ្វើការបូកសរុបលទ្ធផលចាក់វ៉ាក់សាំងជូនយោធិន និងគ្រួសារ ជំហានទី២ នៅក្រោយពេលអនុវត្តចប់ផែនការ ក្នុងរយៈពេល៣ថ្ងៃយ៉ាងយូរ ផ្ញើមកអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិដើម្បីបូកសរុបរាយការណ៍ជូនក្រសួងការពារជាតិ។

**៦**.បណ្តាប្រភេទទ័ព ទ័ពជំនាញ បណ្តាស្ថាប័ន កងឯកភាពចំណុះក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋានអាចទំនាក់ទំនងសាកសួរព័ត៌មានជាមួយលេខាធិការដ្ឋាន អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ តាមរយៈទូរស័ព្ទ និងតេឡេក្រាមដូចខាងក្រោម៖

១-ឧត្តមសេនីយ៍ឯក **ប៉ាង ធារ៉ូ** អគ្គលេខាធិការរង ក្រសួងការពារជាតិ និងជានាយក នាយកដ្ឋានកិច្ចការរដ្ឋបាល និងជាប្រធានលេខាធិការដ្ឋាន (០៩៧ ៨៨៨ ៨៧៧៧)

២-ឧត្តមសេនីយ៍ឯក **គង់ សាលី** អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភាហិរញ្ញវត្ថុ និងជានាយកនាយកដ្ឋានសុខាភិបាល និងជាអនុប្រធានលេខាធិការដ្ឋាន (០៩៧ ៧៦៦ ០៨៣៣)

៣-ឧត្តមសេនីយ៍ឯក **លី សុវណ្ណ** អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភាហិរញ្ញវត្ថុ និងជានាយកមន្ទីរពេទ្យព្រះកេតុមាលា និងជាអនុប្រធានលេខាធិការដ្ឋាន (០៩៧ ៧៧៧ ៧៧៣៣)

៤-ឧត្តមសេនីយ៍ទោ **ព្រំ សត្ថាវុធ** នាយករង នាយកដ្ឋានសុខាភិបាល និងជាអនុប្រធានលេខាធិការដ្ឋាន (០៩៧ ៧៥១ ៣១៦២)

៥-ឧត្តមសេនីយ៍ទោ **ធន សុខេង** នាយករង នាយកដ្ឋានបុគ្គលិក (០១២ ៧១៤ ៦៧០)

៦-ឧត្តមសេនីយ៍ទោ **កៅ វុធ** នាយករង ទីចាត់សុខាភិបាល អគ្គបញ្ជាការដ្ឋាន (០៩៧ ៧៥១ ១២០២)

៧-ឧត្តមសេនីយ៍ត្រី **សេង ឈុន** នាយករង មន្ទីរពេទ្យព្រះកេតុមាលា (០១២ ៨៩២ ១២០)

៨-ឧត្តមសេនីយ៍ត្រី **សុខ ហេង** នាយលេខាធិការដ្ឋាន ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន (០៩៧ ៧៨៥ ២៣៣៦)

៩-វរសេនីយ៍ឯក **អោក ប៊ុណ្ណារិទ្ធ** នាយទាហាន ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន (០៩៧ ៧៣៣ ៣៣៧៧)

សេចក្តីដូចបានជម្រាបខាងលើ សូម**ឯកឧត្តម**ជ្រាបនិងចាត់វិធានការតាមការគួរ ។

សូម**ឯកឧត្តម**ទទួលនូវការរាប់អានអំពីខ្ញុំ។

**រដ្ឋលេខាធិការប្រចាំការ ក្រសួងការពារជាតិ និងជាប្រធាន**
**អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ កពជ**

**នាយឧត្តមសេនីយ៍.នាង_ផាត**

**ចម្លងជូន៖**

-ឯកឧត្តម អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ
-ឯកឧត្តម អនុប្រធានអនុគណៈកម្មការចំពោះកិច្ច
-ឯកឧត្តម នាយកខុទ្ទកាល័យ សម្តេចពិជ័យសេនា
(ដើម្បីជូនជ្រាប)
-លេខាធិការដ្ឋាន អនុគណៈកម្មការចំពោះកិច្ច
-ក្រុមការងារ អនុគណៈកម្មការចំពោះកិច្ច
(ដើម្បីមុខការ)
-ឯកសារ កាលប្បវត្តិ